# ការចុះឈ្មោះអ្នកបោះឆ្នោត មានភាពមិនប្រក្រតីមួយចំនួនគួរឱ្យកត់សម្គាល់

ខុមហ្វ្រែលបានធ្វើការសង្កេតការណ៍ជាប្រចាំ លើដំណើរការស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះ បោះឆ្នោត ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានធ្វើការកំណត់ នៅក្នុងរយៈពេលចាប់ពីថ្ងៃទី ០១ ខែតុលា ដល់ថ្ងៃទី ២០ តុលា ឆ្នាំ២០០៦នេះ។ ហើយ ចំនួនអ្នកចុះឈ្មោះបោះឆ្នោត ដែលបានឱ្យដឹងដោយគ.ជ.ប គិតត្រឹមថ្ងៃទី ៩ តុលា ២០០៦ នៅទូទាំង២៤ខេត្ត-ក្រុងលើឃុំ-សង្កាត់ចំនួន ១.៥៤៥ មានចំនួន២៧៣.៧៨៨នាក់ ក្នុងចំណោមចំនួនប៉ាន់ស្មានសរុបរបស់គ.ជ.ប នូវអ្នកមានសិទ្ធិបោះឆ្នោតត្រូវចុះឈ្មោះបោះឆ្នោតឆ្នាំ២០០៦ ចំនួន ៥៧៧.២០៥នាក់។[១] ទោះយ៉ាងណាក៏ដោយ ដំណើរការ ពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតបានប្រព្រឹត្តទៅជាមួយនឹងការរកឃើញបញ្ហា និងមានភាពមិនប្រក្រតីមួយចំនួន។

ខុមហ្វ្រែលបានធ្វើការសង្កេតលើដំណើរការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះនៅតាមឃុំ សង្កាត់ និងបានដាក់អ្នក សង្កេតការចំនួនជាង ៤០០នាក់។ យោងតាមរបាយការណ៍ជាបឋម ដែលខុមហ្វ្រែលជ្រើសរើសដោយចៃដន្យ អំពីឃុំ សង្កាត់ មួយចំនួនបានបង្ហាញពីភាពមិនប្រក្រតី ក្នុងកំឡុងពេលចុះឈ្មោះបោះឆ្នោត និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត ដូចជា អំពីការមិន គោរពពេលវេលាធ្វើការ ដោយចូលធ្វើការយឺត សម្រាកយូរ និងចេញមុនម៉ោង។ ភាពមិនប្រក្រតីអំពីការមិនគោរពពេលវេលា ធ្វើការរបស់ស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ ខាងលើនេះ មានដូចជានៅឃុំដងទង់ ស្រុកស្មាច់មានជ័យ ខេត្តកោះកុង ឃុំកំពង់រទេះ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ឃុំឡាបានសៀក និងឃុំក្រចាញនៃស្រុកបានលុង ខេត្តរតនគិរី ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ឃុំស្រះឫស្សី ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ឃុំទន្សាយរៈ និងឃុំ សំរោងនៃស្រុកសំរោង ខេត្តឧត្តរមានជ័យ សង្កាត់ទួលល្វា ខណ្ឌប៉ៃលិន ឃុំត្រពាំងប្រាសាទ និងឃុំបានលុងនៃស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

ការមិនគោរពគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃលេខ ០០៨ សណន ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០០៦ ដែល បានធ្វើការផ្សព្វផ្សាយឱ្យគ្រប់ខេត្ត-ក្រុងធ្វើការណែនាំបន្តដល់ *អាជ្ញាធរគ្រប់លំដាប់ថ្នាក់ (ស្រុក ខណ្ឌ ឃុំ សង្កាត់) និងអង្គការ ស្ថាប័ននានាដែលមានសកម្មភាពក្នុងដែនដីរបស់ខ្លួន មិនត្រូវផ្តល់ការងារណាមួយផ្សេងទៀតដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និង ស្មៀនឃុំ សង្កាត់ បំពេញក្រៅពីការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០០៦*[២] ប៉ុន្តែមានការបិទទ្វារ ជារឿយៗនូវការិយាល័យចុះឈ្មោះបោះឆ្នោតនៅឃុំ-សង្កាត់មួយចំនួន ក្នុងចំណោមឃុំ-សង្កាត់ដែលត្រូវបានសង្កេត ដោយសារ មានការកោះប្រជុំពីសំណាក់អាជ្ញាធរមូលដ្ឋាន និង/ឬ ដោយមានការកោះប្រជុំគណបក្ស ឬដោយព្រឹត្តិហេតុផ្សេងៗ។ ជាក់ស្តែង បញ្ហានេះមានដូចជា នៅព្រឹកថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៦ ការិយាល័យចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត សង្កាត់ផ្សារ ដេប៉ូ១ ផ្សារដេប៉ូ២ ផ្សារដេប៉ូ៣ និងបឹងកក់១ ត្រូវបិទទ្វារ ដោយសារតែអាជ្ញាធរក្រុងភ្នំពេញកោះហៅក្រុមប្រឹក្សាសង្កាត់ និងស្មៀនទៅប្រជុំនៅសាលាក្រុង ហើយករណីបិទទ្វារការិយាល័យចំនួន៤ថ្ងៃ ដោយហេតុផលផ្សេងៗក៏កើតមានឡើងនៅ ឃុំផ្លូវទូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំងផងដែរ។

---

[១] Preliminary Results of Voter List Revision and Voter Registration as of October 9th, 2006, National Election Committee, No 10.134/06, Phnom Penh, October 12th, 2006

[២] ក្រសួងមហាផ្ទៃ គោលការណ៍ណែនាំសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០០៦ លេខ ០០៨សណន ភ្នំពេញ ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០០៦។

ការសង្កេតរកឃើញដែរថា នៅឆ្នាំនេះ ភ្នាក់ងារគណបក្សនយោបាយមកពីគណបក្សប្រជាជនកម្ពុជា គណបក្ស សមរង្ស៊ី គណបក្សហ្វ៊ុនស៊ិនប៉ិចបានចូលរួមយ៉ាងសកម្ម ដែលមិនគ្រាន់តែនៅក្នុងការសង្កេតដំណើរការចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានចូលរួមជួយអប់រំផ្សព្វផ្សាយ និងថតរូបដល់ប្រជាពលរដ្ឋ ដើម្បីបិទលើពាក្យសុំទម្រង់ ១០១៨។ ប៉ុន្តែសកម្មភាពខ្លះត្រូវបានរារាំងពីអាជ្ញាធរឃុំ សង្កាត់ ដូចជាការចែកខិតប័ណ្ណ និងផ្សព្វផ្សាយអប់រំអំពីការបោះឆ្នោតរបស់ភ្នាក់ងារគណបក្សនយោបាយ ហើយជាក់ស្តែងបញ្ហានេះកើតឡើងចំពោះគណបក្សសម រង្ស៊ី នៅតាមសង្កាត់មួយចំនួននៅក្នុងរាជធានីភ្នំពេញ និងនៅឃុំមួយចំនួននៅខេត្តកំពង់ចាម។ ការរារាំងនោះបានត្រូវអះអាងថា អាជ្ញាធរឃុំ សង្កាត់ត្រូវការត្រួតពិនិត្យឯកសារជាមុនសិន បើទោះបីមន្ត្រីគ.ជ.ប បានអះអាងថា ភ្នាក់ងារគណបក្សមានសិទ្ធិផ្សព្វផ្សាយអប់រំដល់អ្នកមានសិទ្ធិបោះឆ្នោតក៏ដោយ។

បញ្ហាសំខាន់មួយផ្សេងទៀតពាក់ព័ន្ធនឹងការផ្តល់ឯកសារអត្តសញ្ញាណប័ណ្ណដល់ប្រជាពលរដ្ឋ មានការសង្កេតឃើញថា ក្រសួងមហាផ្ទៃមិនមានការសម្រួល និងគ្មានការទទួលខុសត្រូវចំពោះការងាររបស់ខ្លួននោះឡើយ ហើយជាលទ្ធផល ការបញ្ជាក់ទម្រង់ ១០១៨ មានការកើនឡើងច្រើនគួរឱ្យកត់សម្គាល់។ លើសពីនេះទៀត មិនត្រឹមតែចំពោះអ្នកមិនមានអត្តសញ្ញាណប័ណ្ណប៉ុណ្ណោះទេ ដែលអាចត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិបោះឆ្នោតរបស់ពួកគាត់ ប៉ុន្តែអ្នកមានអត្តសញ្ញាណប័ណ្ណហើយ ក៏ត្រូវបានរកឃើញថា ទទួលរងការប៉ះពាល់ផងដែរ ជាក់ស្តែងដូចជាករណីប្រជាពលរដ្ឋរស់នៅភូមិឫស្សីជ្រោយ ឃុំកំពង់លួង ស្រុកពញាឮ ដែលគ្រួសារចំនួន ៩៦ ត្រូវបានរាយការណ៍ថា ត្រូវបានដកហូតអត្តសញ្ញាណប័ណ្ណ ដោយការពាក់ព័ន្ធនឹងទិញ-លក់ដីជាមួយក្រុមហ៊ុន ផាន អ៊ី ម៉ិច ហើយដូច្នេះអាចប៉ះពាល់ដល់សិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋ។

ចំពោះការបញ្ជាក់អត្តសញ្ញាណ តាមរយៈទម្រង់បែបបទលេខ១០១៨ គ.ជ.បបានសម្រេចរក្សាសុពលភាពចំពោះលិខិតធានាអះអាងពីអត្តសញ្ញាណដែលមេឃុំបានបញ្ជាក់ជូនប្រជាពលរដ្ឋតាំងពីការបោះឆ្នោតឆ្នាំ២០០៣ ហើយការនេះធ្វើឱ្យគ.ជ.ប ធ្វើការអះអាងថា លិខិតធានាអះអាងពីអត្តសញ្ញាចំនួន ៤០០.០០០ កំពុងតែទទួលបានសុពលភាពប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត ឬប្រើប្រាស់ក្នុងការបោះឆ្នោតនៅថ្ងៃបោះឆ្នោតបាន។ ហើយថែមទាំងបានធ្វើការបញ្ជាក់ថា ទម្រង់១០១៨នេះអាចទៅយកពីមេឃុំ ឬចៅសង្កាត់ពេលណាក៏បាន ដោយត្រូវនាំសាក្សី២នាក់ ដែលជាអ្នកមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំសង្កាត់នោះទៅជាមួយដើម្បីអះអាងអំពីអត្តសញ្ញាណ ទីលំនៅ ឬអាយុរបស់អ្នកសុំ និងម្យ៉ាងទៀត ថែមទាំងសម្រួលការបិទរូបថតរបស់អ្នកដាក់ពាក្យសុំបញ្ជាក់ទម្រង់១០១៨នេះទៀតផង ដោយអាចធ្វើការបញ្ជាក់ដោយមិនមានបិទរូបថត ដើម្បីចុះឈ្មោះបោះឆ្នោតសិនបាន ប៉ុន្តែត្រូវយកទៅបិទនៅចំពោះមុខមន្ត្រីទទួលបន្ទុកចុះឈ្មោះបោះឆ្នោតនៃសាលាឃុំសង្កាត់នោះ នៅពេលមានរូបថត។ យ៉ាងណាក៏ដោយ ខុមហ្វ្រែលរកឃើញថា បញ្ហានៃការស្វែងរករូបថតរបស់ប្រជាពលរដ្ឋកម្ពុជាក្រីក្រនៅតាមជនបទដាច់ស្រយាលប្រហែល៣០០ ឃុំ សង្កាត់ នៅតែមានជួបការលំបាក មិនមានរូបថតបិទលើទម្រង់ ១០១៨។

បើទោះបីនីតិវិធីចុះឈ្មោះ និងការធ្វើទម្រង់១០១៨ តម្រូវឱ្យមានសាម៉ីខ្លួនទៅបង្ហាញខ្លួននៅចំពោះមុខស្មៀនឃុំ ឬមេឃុំចៅសង្កាត់ ដើម្បីចុះឈ្មោះបាន ក្នុងការអនុវត្តជាក់ស្តែងនៅតាមសង្កាត់មួយចំនួននៅក្នុងរាជធានីភ្នំពេញ មានការចុះឈ្មោះបោះឆ្នោតដោយមិនចាំបាច់មានវត្តមានរបស់សាម៉ីជនដាក់ពាក្យសុំឡើយ ដោយគ្រាន់តែធ្វើអត្តសញ្ញាណប័ណ្ណតាមរយៈបងប្អូនតែប៉ុណ្ណោះ។ មានការព្រួយបារម្ភថា ការអនុញ្ញាតឱ្យបំពេញទម្រង់ ១០១៨ ដោយមិនចាំបាច់មានរូបថតជាមុននោះ ទំនងជាមូលហេតុមួយ ដែលបង្កឱ្យមានអវត្តមានរបស់សាម៉ីជនដាក់ពាក្យសុំចុះឈ្មោះបោះឆ្នោតអាចប្រព្រឹត្តទៅបានដោយងាយស្រួល។

ក្រៅពីភាពមិនប្រក្រតីខាងលើនេះ ខុមហ្វ្រែលក៏បានរកឃើញនូវបញ្ហាយ៉ាងគួរឱ្យកត់សម្គាល់មួយចំនួន ដូចជាការបាត់ឈ្មោះប្រជាពលរដ្ឋដែលធ្លាប់បោះឆ្នោតឆ្នាំ២០០៣ ភាពខុសគ្នាច្រើនរហូតដល់ទៅចំនួន ១៣,១៣% រវាងឯកសារ និងបញ្ជីឈ្មោះផ្លូវការ២០០៥របស់គ.ជ.បនៅតាមខេត្ត-ក្រុងចំនួន១៣ និងតាមការពិនិត្យបញ្ជីឈ្មោះប្រជាពលរដ្ឋផ្លូវការ២០០៥ ក៏មានការរកឃើញករណីមានឈ្មោះ ប៉ុន្តែអត់មានមនុស្ស (អ្នកបោះឆ្នោតខ្មោច?) ចំនួន ១០,១៣%ផងដែរនៅ តាមខេត្ត-ក្រុងចំនួន ២៣។ ដោយឡែក បញ្ហានៃការអនុវត្តនីតិវិធីផ្តល់ប័ណ្ណអ្នកសង្កេតការណ៍ក៏មានជួបប្រទះការលំបាក និងចំណាយពេលវេលាយូរមិនចាំបាច់ ជាក់ស្តែងការដាក់ពាក្យសុំរបស់អង្គការខុមហ្វ្រែលត្រូវចំណាយពេលច្រើន ដែលការនេះធ្វើឱ្យប៉ះពាល់ដល់ការងារសង្កេតការចុះឈ្មោះបោះឆ្នោតនៅក្នុងទីស្នាក់នៅតាមខេត្តមួយចំនួន ហើយបើការនេះនៅតែបន្ត នោះវាទំនងជាបញ្ហាចម្បងមួយដល់ការងារ និងអ្នកសង្កេតការរយៈពេលខ្លី ដែលមានចំនួនច្រើន (ជាង៩០០០នាក់ ពីអង្គការខុមហ្វ្រែលតែមួយ) នៅអំឡុងពេលបោះឆ្នោត។ ជាការប្រសើរ គ.ជ.បគួរត្រឹមតែទទួលការចុះបញ្ជីរបស់អង្គការសង្កេតការណ៍បោះឆ្នោត ហើយសម្រួលដល់ការលំបាករបស់អង្គការសង្កេតការបោះឆ្នោត ដែលចំណាយពេលវេលា និងអស់សោហ៊ុយច្រើន ក្នុងការផ្ញើបញ្ជូនប័ណ្ណសង្កេតការឱ្យទៅដល់អ្នកសង្កេតការណ៍នៅទូទាំងប្រទេសមានលទ្ធភាពចុះធ្វើការសង្កេតការឱ្យទាន់ពេលវេលា។ គ.ជ.បតែងតែមិនទទួលយកមតិ ក្នុងការសម្រួលការយកប័ណ្ណអ្នកសង្កេតការណ៍ ដោយមិនផ្តល់សិទ្ធិឱ្យដល់គណៈកម្មការរៀបចំការបោះឆ្នោតខេត្ត-ក្រុង ជាអ្នកសម្រេចលើបញ្ជីឈ្មោះអ្នកសង្កេតការណ៍បានលឿនជាង។

ទោះជាមានភាពមិនប្រក្រតីជាបន្តបន្ទាប់ និងជារឿយៗក៏ដោយ ក៏មានការសង្កេតឃើញផងដែរថា គ.ជ.បបានបញ្ចេញសកម្មភាពសស្រាក់សស្រាំ មានការខិតខំប្រឹងប្រែង ឆ្លើយតបជាវិជ្ជមានច្រើន បើប្រៀបធៀបទៅនឹងការងាររបស់គ.ជ.ប កាលពីការបោះឆ្នោតកន្លងមក ជាក់ស្តែងមានការរៀបចំផែនការអនុវត្តថ្មីៗ ដែលមានគោលបំណងជួយបង្កើនការចុះឈ្មោះ ដោយបន្ថែមជំនួយការស្មៀនសម្រាប់ឃុំ-សង្កាត់ ដែលមានប្រជាពលរដ្ឋច្រើន និងមានក្រុមចល័តចុះឈ្មោះបោះឆ្នោតដល់ភូមិជាច្រើននៅតំបន់ដាច់ស្រយាល ការចេញផ្សាយព័ត៌មានបូកលទ្ធផល ការជូនដំណឹង ការឆ្លើយតបជាអន្តរាគមន៍នានាកាន់តែមានសកម្មភាពឡើង។ ម្យ៉ាងវិញទៀត ល្បឿននៃការចុះឈ្មោះនាពេលនេះកំពុងលុបបំបាត់ការព្រួយបារម្ភអំពីការចុះឈ្មោះមិនទាន់ពេលវេលា ពោលគឺគ.ជ.ប សម្រេចបានលទ្ធផលជាបឋមគួរឱ្យកត់សម្គាល់។ គួរបញ្ជាក់ដែរថា តាមការសង្កេតរបស់ខុមហ្វ្រែល ល្បឿននៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោតក្នុង១ថ្ងៃ ជាមធ្យម សម្រេចបានក្នុងចំនួនច្រើនជាងចំនួនជាមធ្យមក្នុងរយៈពេលដូចគ្នានេះ កាលពីឆ្នាំ២០០៤ និង ២០០៥ ប៉ុន្តែនៅ យឺតជាងកាលពីឆ្នាំ២០០៣។

ដោយសារមូលហេតុជាច្រើន រួមមាននីតិវិធីនៃការចុះឈ្មោះបោះឆ្នោតមានលក្ខណៈស្មុគស្មាញ និងខុសប្លែកពីនីតិវិធីមុនៗ និងមានការរារាំងពីអាជ្ញាធរផង ធ្វើឱ្យមានការមិនយល់ច្បាស់ និងការភាន់ច្រឡំមួយចំនួន ម្យ៉ាងដោយសារតែការផ្សព្វផ្សាយរបស់គ.ជ.ប នៅមានកម្រិត និងមិនមានប្រសិទ្ធភាពនៅឡើយ។ ដើម្បីកាត់បន្ថយភាពមិនប្រក្រតីមួយចំនួនខាងលើនេះ គ.ជ.បគួរពិចារណាបន្ថែមទៀតលើការរៀបចំចាត់ចែងម៉ាស៊ីនថតរូប និងការថតរូបឱ្យដល់ប្រជាពលរដ្ឋ ដែលរស់នៅទីជនបទដាច់ស្រយាល ហើយទន្ទឹមនឹងនេះ គ.ជ.បក៏គួរមានគោលការណ៍ណែនាំនិងសហការជាមួយអាជ្ញាធរឃុំ សង្កាត់ឱ្យបានរលូនក្នុងការអប់រំផ្សព្វផ្សាយការងារបោះឆ្នោត។

ខុមហ្វ្រែល អ្នកឃ្លាំមើល ថ្ងៃសុក្រ ទី១៣ ខែតុលា ឆ្នាំ២០០៦